ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៣៣៣៦ មស.៩៤៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០១៩

**យោង ៖** - លិខិតលេខ១០៩៧ មស.ក្រខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ៣១៤១ មស.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ឱ្យបានជ្រាបថា ក្រសួងមុខងារសាធារណៈ សម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិតនិងមន្ត្រីរាជការស៊ីវិលសរុបចំនួន **១៤៥កន្លែង** ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំង០៤ សម្រាប់ឆ្នាំ២០១៩ រួមមាន៖

**១-ក្រសួងមុខងារសាធារណៈ** ចំនួន ០៣កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។

**២-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច** ចំនួន ០៦កន្លែង សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។

**៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ចំនួន **១២០កន្លែង** សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។ បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬ សញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| I. **ទីស្តីការក្រសួង ជ្រើសរើសក្របខណ្ឌចំនួន ៥៥កន្លែង** | | | | | |
| ១ | ន. កិច្ចការរដ្ឋបាល | វិទ្យាសាស្ត្រគ្រប់គ្រង | ០១ | ០១ | |
| ២ | ន. គណនេយ្យ ហិរញ្ញវត្ថុ | ព័ត៌មានវិទ្យា | ០១ | ០១ | |
| ៣ | ន. សវនកម្មផ្ទៃក្នុង | វិទ្យាសាស្ត្រគ្រប់គ្រង | ០១ | ០១ | |
| ៤ | ន. ផែនការនិងស្ថិតិ | នីតិសាស្ត្រ | ០១ | ០១ | |
| ៥ | ន. សហប្រតិបត្តិការអន្តរជាតិ | ភាសាអង់គ្លេស | ០១ | ០១ | |



ផ្លូវវេត្តអង្គតាម៉ិញ កូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| ៦ | ន.បុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | វិទ្យាសាស្ត្រគ្រប់គ្រង | ០២ | ០១ | |
| | | នីតិសាស្ត្រ | | ០១ | |
| ៧ | អគ្គាធិការដ្ឋាន | វិទ្យាសាស្ត្រគ្រប់គ្រង | ០១ | ០១ | |
| ៨ | ន. នីតិកម្មកសិកម្ម | គីមីវិទ្យានិងចំណីអាហារ | ០១ | ០១ | |
| ៩ | អគ្គ.សុខភាពសត្វ និងផលិតកម្មសត្វ | ផលិតកម្មនិងបសុ | ០៤ | ០២ | ០១ |
| | | នីតិសាស្ត្រ | | ០១ | |
| ១០ | ន.កសិ.ឧស្សាហកម្ម | គីមីវិទ្យានិងចំណីអាហារ | ០២ | ០១ | |
| | | ព័ត៌មានវិទ្យា | | ០១ | |
| ១១ | រដ្ឋបាលជលផល | ជលផល | ០៤ | ០៣ | ០១ |
| ១២ | រដ្ឋបាលព្រៃឈើ | រុក្ខកម្ម | ០៤ | ០៣ | ០១ |
| ១៣ | អគ្គនាយកដ្ឋានកសិកម្ម | ក្សេត្រសាស្ត្រ | ០៨ | ០៥ | ០៣ |
| ១៤ | អគ្គនាយកដ្ឋានកៅស៊ូ | កៅស៊ូ | ០២ | ០១ | ០១ |
| ១៥ | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ក្សេត្រសាស្ត្រ | ០៣ | ០២ | |
| | | គីមីវិទ្យានិងចំណីអាហារ | | ០១ | |
| ១៦ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | កៅស៊ូ | ០៥ | ០៣ | |
| | | គីមីវិទ្យានិងចំណីអាហារ | | ០២ | |
| ១៧ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ក្សេត្រសាស្ត្រ | ០៤ | ០១ | |
| | | កសិ.ឧស្សាហកម្ម | | ០១ | |
| | | វិស្វកម្មកសិកម្ម(ធារាសាស្ត្រ) | | ០១ | |
| | | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | | ០១ | |
| ១៨ | សាលាជាតិកសិកម្មព្រែកលៀប | ផលិតកម្ម និងបសុ | ០២ | ០១ | |
| | | គីមីវិទ្យានិងចំណីអាហារ | | ០១ | |
| ១៩ | សាលាជាតិកសិកម្មកំពង់ចាម | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | ជលផល | | ០១ | |
| ២០ | មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម | វិទ្យាសាស្ត្រគ្រប់គ្រង | ០១ | ០១ | |
| ២១ | ន.ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ក្សេត្រសាស្ត្រ | ០៤ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | សេដ្ឋកិច្ចកសិកម្ម និងអភិ.ជនបទ | | ០១ | |
| | | ព័ត៌មានវិទ្យា | | ០១ | |
| II. **មន្ទីររាជធានី ខេត្ត ជ្រើសរើសក្របខណ្ឌចំនួន ៦៥កន្លែង** | | | | | |
| ១ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ | ផលិតកម្ម និងបសុ | ០១ | ០១ | |
| ២ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្ដាល | ក្សេត្រសាស្ត្រ | ០១ | ០១ | |
| ៣ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ | ក្សេត្រសាស្ត្រ | ០២ | | ០១ |
| | | វិស្វកម្មកសិកម្ម(ធារាសាស្ត្រ) | | ០១ | |

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| ៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ជលផល | | ០១ | |
| ៥ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | ជលផល | | ០១ | |
| ៦ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ | ជលផល | ០១ | ០១ | |
| ៧ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ជលផល | | ០១ | |
| ៨ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| ៩ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | វិទ្យាសាស្ត្រគ្រប់គ្រង | | ០១ | |
| ១០ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន | ក្សេត្រសាស្ត្រ | ០២ | | ០១ |
| | | ផលិតកម្ម និងបសុ | | ០១ | |
| ១១ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | រុក្ខកម្ម | | ០១ | |
| ១២ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | ជលផល | | ០១ | |
| ១៣ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ជលផល | | ០១ | |
| | | វិស្វកម្មកសិកម្ម(ជាវសាស្ត្រ) | | ០១ | |
| ១៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម | ក្សេត្រសាស្ត្រ | ០៤ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | ជលផល | | ០១ | |
| | | រុក្ខកម្ម | | ០១ | |
| ១៥ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ | ក្សេត្រសាស្ត្រ | ០៥ | ០១ | ០១ |
| | | ផលិតកម្ម និងបសុ | | ០១ | ០១ |
| | | វិស្វកម្មកសិកម្ម(ជាវសាស្ត្រ) | | ០១ | |
| ១៦ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ជលផល | | ០១ | |
| | | រុក្ខកម្ម | | ០១ | |
| ១៧ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តរតនគីរី | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| ១៨ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគីរី | ក្សេត្រសាស្ត្រ | ០៥ | ០១ | ០១ |
| | | ផលិតកម្ម និងបសុ | | ០១ | ០១ |
| | | សេដ្ឋកិច្ចកសិកម្ម និងអភិ.ជនបទ | | ០១ | |

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| ១៩ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | សេដ្ឋកិច្ចកសិកម្ម និងអភិ.ជនបទ | | ០១ | |
| ២០ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង | ក្សេត្រសាស្ត្រ | ០៤ | ០១ | ០១ |
| | | ផលិតកម្ម និងបសុ | | ០១ | ០១ |
| ២១ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| ២២ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | ជលផល | | ០១ | |
| ២៣ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ | ក្សេត្រសាស្ត្រ | ០៣ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| | | វិទ្យាសាស្ត្រគ្រប់គ្រង | | ០១ | ០១ |
| ២៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង | ក្សេត្រសាស្ត្រ | ០៤ | ០១ | ០១ |
| | | ផលិតកម្ម និងបសុ | | ០១ | ០១ |
| ២៥ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | ក្សេត្រសាស្ត្រ | ០២ | ០១ | |
| | | ផលិតកម្ម និងបសុ | | ០១ | |
| សរុបរួម | | | ១២០ | ១០៤ | ១៦ |

**៤-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** ចំនួន **១៦កន្លែង** សម្រាប់បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ឬ សញ្ញាបត្រសមមូល។ បេក្ខជនប្រឡងក្របខណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្ររងឡើងទៅ ឬ សញ្ញាបត្រសមមូល ដូចមានបែងចែកតាមអង្គភាពខាងក្រោម៖

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| ១ | អាកាសយានដ្ឋានអន្តរជាតិសៀមរាប | ១.អក្សរសាស្ត្រអង់គ្លេស<br>២.ព័ត៌មានវិទ្យា<br>៣.រដ្ឋបាលសាធារណៈ<br>៤.ហិរញ្ញវត្ថុនិងធនាគារ<br>៥.សេដ្ឋកិច្ច | ០២ | ០២ | |
| ២ | អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | ១.អក្សរសាស្ត្រអង់គ្លេស<br>២.ព័ត៌មានវិទ្យា<br>៣.ទំនាក់ទំនងអន្តរជាតិ<br>៤.នីតិសាស្ត្រ<br>៥.គណនេយ្យ | ០២ | ០២ | |
| ៣ | សេវាកម្មអាកាសចរណ៍ | ១.ព័ត៌មានវិទ្យា<br>២.វិស្វកម្មអគ្គីសនីនិងអេឡិចត្រូនិក<br>៣.អក្សរសាស្ត្រអង់គ្លេស<br>៤.គណនេយ្យ/គ្រប់គ្រង<br>៥.វិទ្យាសាស្ត្រសេដ្ឋកិច្ច | ០៣ | ០៣ | |

| ល.រ | អង្គភាព | ជំនាញ/ឯកទេស | ចំនួនជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|
| | | | | ក | ខ |
| ៤ | ន.ទំនាក់ទំនងអន្តរជាតិ នីតិកម្ម | ១.អក្សរសាស្ត្រអង់គ្លេស<br>២.ព័ត៌មានវិទ្យា<br>៣.រដ្ឋបាលសាធារណៈ<br>៤.ទំនាក់ទំនងអន្តរជាតិ<br>៥.នីតិសាស្ត្រ<br>៦.គ្រប់គ្រង | ០១ | ០១ | |
| ៥ | ន.រដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស | ១.ព័ត៌មានវិទ្យា<br>២.រដ្ឋបាលសាធារណៈ<br>៣.ទំនាក់ទំនងអន្តរជាតិ<br>៤.គណនេយ្យ | ០២ | ០១ | |
| | | បរិញ្ញាបត្ររងឡើងទៅ | | | ០១ |
| ៦ | ន.ផែនការ យុទ្ធសាស្ត្រនិងគោលនយោបាយ | បរិញ្ញាបត្ររងឡើងទៅ | ០១ | | ០១ |
| ៧ | ន.ស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន | ១.វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក<br>២.ព័ត៌មានវិទ្យា<br>៣.អក្សរសាស្ត្រអង់គ្លេស<br>៤.រដ្ឋបាលសាធារណៈ<br>៥.ហិរញ្ញវត្ថុនិងធនាគារ<br>៦.គ្រប់គ្រង<br>៧.សេដ្ឋកិច្ច | ០២ | ០២ | |
| ៨ | ន.លទ្ធភាពហោះហើរ | ១.វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក<br>២.ព័ត៌មានវិទ្យា<br>៣.អក្សរសាស្ត្រអង់គ្លេស<br>៤.គ្រប់គ្រងពាណិជ្ជកម្ម<br>៥.សេដ្ឋកិច្ច | ០២ | ០២ | |
| ៩ | ន.ស្តង់ដា និងសុវត្ថិភាពនាំផ្លូវអាកាស | ១.ព័ត៌មានវិទ្យា<br>២.អក្សរសាស្ត្រអង់គ្លេស<br>៣.រដ្ឋបាលសាធារណៈ | ០១ | ០១ | |
| សរុប | | | ១៦ | ១៤ | ០២ |

**គ-លក្ខខណ្ឌជ្រើសរើស**

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២. លក្ខខណ្ឌអាយុត្រូវបានកំណត់ដូចមានខាងក្រោម៖

- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររងឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ

៣. ចំពោះបេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ

បេក្ខជនជាមន្ត្រីរាជការត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងពីប្រធានក្រសួង ស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ នៅតាមក្រសួង ស្ថាប័ន ឬអង្គភាពណាមួយ ហើយត្រូវបានរៀបចំផ្ទេរក្របខណ្ឌទៅកន្លែងថ្មី បេក្ខជនជាមន្ត្រីរាជការត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ។

**៤. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ**

**៥. ចំពោះបេក្ខជនជានារី ជនពិការ និងអ្នករស់នៅតំបន់ដាច់ស្រយាល ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត**

**៦. សញ្ញាបត្រ ឬ លិខិតបញ្ជាក់ការសិក្សាគ្រប់កម្រិតជំនាញ ត្រូវបានដាក់វិធានការដូចខាងក្រោម៖**

- ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬ លិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះប្រឡងជាប់ក្នុងក្របខណ្ឌក្រសួង ស្ថាប័នណាមួយក៏ដោយ
- ចំពោះសញ្ញាបត្រដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

## ខ-សំណុំលិខិតចុះឈ្មោះសុំសិទ្ធិប្រឡង៖

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤ x ៦) | ចំនួន ០១ច្បាប់ |
| ៣. សលាកបត្រឯកត្តជន | ចំនួន ០១ច្បាប់ |
| ៤. បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |
| ៥. កិច្ចសន្យាការងារ (ផ្អែកតាមលក្ខខណ្ឌតម្រូវរបស់សាមីក្រសួង ស្ថាប័ន) | ចំនួន ០១ច្បាប់ |
| ៦. សេចក្តីចម្លងសញ្ញាបត្រជំនាញ | ចំនួន ០១ច្បាប់ |
| ៧. សេចក្តីថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| ៩. លិខិតអនុញ្ញាតរបស់ប្រធានក្រសួង ស្ថាប័ន (សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |

**បញ្ជាក់៖ រាល់លិខិតស្នាមតម្រូវពាក់ព័ន្ធ ត្រូវមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ។**

## គ-វិញ្ញាសាប្រឡង

### វិញ្ញាសាប្រឡងត្រូវបានកំណត់ដូចខាងក្រោម៖

-ម៉ោងទី១ ចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

-ម៉ោងទី២ មុខវិជ្ជាភាសាអង់គ្លេសនិងកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខណ្ឌ **ក** និង **ខ**

## ឃ-កាលបរិច្ឆេទលក់ពាក្យ ទទួលពាក្យ និងទីកន្លែងទទួលពាក្យ៖

១. កាលបរិច្ឆេទលក់ពាក្យនិងទទួលពាក្យ ចាប់ពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ នេះតទៅរៀងរាល់ម៉ោងធ្វើការពេលព្រឹកចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី

២. កាលបរិច្ឆេទឈប់ទទួលពាក្យនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៧:០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។

**៣. ទីកន្លែងលក់ពាក្យ និងទទួលពាក្យសុំសិទ្ធិប្រឡង៖**

-បេក្ខជនដែលដាក់ពាក្យសុំសិទ្ធិប្រឡងនៅក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវមកទិញពាក្យ និងដាក់ពាក្យសុំសិទ្ធិប្រឡងនៅនាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ នៃក្រសួងមុខងារសាធារណៈ (អគារបែរមុខទៅលិច ជាន់ផ្ទាល់ដី បន្ទប់ A05)។

-បេក្ខជនដែលដាក់ពាក្យសុំសិទ្ធិប្រឡងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងតាមបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវមកទិញពាក្យ និងដាក់ពាក្យសុំសិទ្ធិប្រឡងនៅនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

**បញ្ជាក់៖ បេក្ខជនទាំងអស់ត្រូវមកដាក់ពាក្យសុំសិទ្ធិប្រឡងដោយខ្លួនឯងផ្ទាល់។**

**ខ-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង**

គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹងអំពីកាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡងនៅពេលក្រោយ។ សូមបេក្ខជនទាំងអស់តាមដានព័ត៌មាននៅគេហទំព័ររបស់ក្រសួងមុខងារសាធារណៈតាមរយៈអាសយដ្ឋាន(www.mcs.gov.kh) និងតាមបណ្ដាញគេហទំព័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតាមបណ្ដាញសង្គមហ្វេសប៊ុករបស់ក្រសួងមុខងារសាធារណៈ (http://facebook.com/CivilServiceCambodia/)។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង តំណាងក្រសួង ស្ថាប័នដូចខាងក្រោម៖

១. ក្រសួងមុខងារសាធារណៈ

ទូរស័ព្ទលេខ៖ ០១២ ៣៥១ ១១៤ / ០១៧ ៦៥១ ៣២៣ / ០១២ ៣៣១ ០០៧ / ០៨៩ ៩៧៨ ៦៧៨
០១២ ៣០៥ ៥៣០ / ០១៧ ៩០០ ១២៩ / ០១២ ៧៩១ ៨៩១ / ០៨៧ ៧៧៧ ៩០៧

២.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទូរស័ព្ទលេខ៖ ០១២ ៧២៧ ៦៦៤ / ០១២ ៩១៦ ៩០៤ / ០៩៩ ៩១១ ១២៤ / ០១២ ៥៣៧ ៣៧៣

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមរួសរាន់មកទិញពាក្យសុំសិទ្ធិប្រឡងដើម្បីបំពេញសំណុំបែបបទប្រឡងប្រជែងជ្រើសរើសតាមក្រសួង ស្ថាប័ន ណាមួយដែលខ្លួនមានបំណងចង់ចូលបម្រើការងារ ដូចបានរៀបរាប់ខាងលើនេះ។

បញ្ជាក់៖ **បេក្ខជនអាចដាក់ពាក្យសុំសិទ្ធិប្រឡងបានតែមួយក្រសួង ស្ថាប័ន តែប៉ុណ្ណោះ**។

កំណត់សម្គាល់៖ ក្រសួងមុខងារសាធារណៈ សូមរក្សាសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់៕

ថ្ងៃចន្ទ ១៤ កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋលេខាធិការនិងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ឡៅ ច័ន្ទប៊ុនធឿន**

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
" ដើម្បីសហការអនុវត្ត និងជួយផ្សព្វផ្សាយ "
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៣៣៧ មស.ក្រខ

ថ្ងៃចន្ទ ១៤ កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៩

# បទបញ្ញត្តិ

## សម្រាប់បេក្ខជនប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំងមូល ឆ្នាំ២០១៩

ដើម្បីរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងឱ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពតាមបទប្បញ្ញត្តិនៃការប្រឡង ដូចខាងក្រោម៖

១. ប្រការដែលបេក្ខជនត្រូវអនុវត្ត

- ត្រូវមកដល់មណ្ឌលប្រឡង មុនចាប់ផ្ដើមដំណើរការប្រឡងរយៈពេល ៣០នាទី
- ត្រូវស្លៀកសំលៀកបំពាក់សមរម្យ
- ត្រូវយកមកជាមួយនូវសលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណសំគាល់ខ្លួនសិស្ស និស្សិត និងមន្ត្រីរាជការ
- ត្រូវអនុវត្តតាមការណែនាំរបស់ប្រធានអនុគណៈកម្មការមេប្រយោគ និងប្រធានអនុគណៈកម្មការអនុរក្ស
- ត្រូវរក្សារបៀបរៀបរយ និងភាពស្ងៀមស្ងាត់នៅក្នុងពេលប្រឡង
- ត្រូវប្រើប៊ិចឃ្លីដែលមានទឹកពណ៌ខៀវ
- បេក្ខជនត្រូវបង្កលក្ខណៈងាយស្រួលឱ្យអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ ហើយត្រូវគោរពតាមសំណូមពររបស់អ្នកត្រួតពិនិត្យក្នុងការដកហូតនូវសម្ភារ ឬ របស់អ្វីៗដែលគ្មានការអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡង
- ត្រូវគោរពវិន័យនៃការប្រឡងដោយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយនិងសណ្ដាប់ធ្នាប់នៃការប្រឡងដូចជា បេក្ខជនត្រូវអង្គុយតាមលេខតុដែលអនុរក្សបង្ហាញ សរសេរឈ្មោះនិងលេខតុនៅលើក្បាលសន្លឹកកិច្ចការប្រឡងដែលអនុរក្សចែកជូន និងប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សប្រចាំបន្ទប់វិញ ទោះបីជាសន្លឹកកិច្ចការប្រឡងនោះមិនសរសេរចម្លើយ ឬ ដំណោះស្រាយអ្វីក៏ដោយ។ បេក្ខជនដែលមិនប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សវិញ ត្រូវចាត់ទុកថាអវត្តមាន។

២. ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត

- ហាមដាច់ខាតសេពគ្រឿងស្រវឹង
- ហាមយកអាវុធ ឬ គ្រឿងផ្ទុះគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង
- ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទដែលមានផ្ទុកឯកសារចូលក្នុងបន្ទប់ប្រឡង
- មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឡើយ
- ហាមចម្លងចម្លើយពីអ្នកជិតខាង ឬ បង្កលក្ខណៈឱ្យអ្នកដទៃចម្លង ឬ សរសេរហើយអានខ្លាំងៗឮដល់បេក្ខជនដទៃទៀតក្នុងពេលកំពុងធ្វើវិញ្ញាសា
- ហាមប្ដូរសន្លឹកកិច្ចការប្រឡង ដើម្បីឱ្យអ្នកដទៃជួយកែ និងមិនត្រូវស្នើឱ្យអ្នកដទៃជួយពន្យល់
- ហាមប្រើទឹកលុបសម្រាប់លុបកំហុសផ្សេងៗ លើសន្លឹកកិច្ចការប្រឡង

រដ្ឋលេខាធិការ និងជា
ប្រធានគណៈកម្មការរៀបចំការប្រឡង

ខៀវ ច័ន្ទប៊ុនធឿន

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh